**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៦៤៩ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**<u>កម្មវត្ថុ:</u>** អំពីការអញ្ជើញចូលបំភ្លឺដោយផ្ទាល់មាត់ នៅរដ្ឋសភាលើគោលនយោបាយរាជរដ្ឋាភិបាលក្នុងការទប់ទល់នឹងផលវិបាកបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោក និង កិច្ចការសេដ្ឋកិច្ចផ្សេងទៀតមួយចំនួន ។

**<u>យោង:</u>** លិខិតលេខ ស.ឆ ៤-០០២/០៩ រ.ស ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ របស់ ឯកឧត្តម តំណាងរាស្ត្រ សុន ឆ័យ ដោយមានសេចក្តីបញ្ជាក់បញ្ជូនលេខ ០៨៥ រ.ស ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបសម្តេចប្រធានរដ្ឋសភា មេត្តាជ្រាបថា ខ្ញុំបានទទួលលិខិតរបស់ឯកឧត្តមតំណាងរាស្ត្រ សុន ឆ័យ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ ដោយមាន សេចក្តីបញ្ជាក់ បញ្ជូនលេខ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ដូចមានគោរពជូនភ្ជាប់មកជាមួយនេះ ដើម្បីស្នើអញ្ជើញរូបខ្ញុំឱ្យចូលបំភ្លឺផ្ទាល់មាត់ នៅរដ្ឋសភា « លើគោលនយោបាយរាជរដ្ឋាភិបាល ក្នុងការទប់ទល់ នឹងផលវិបាកបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោក និង កិច្ចការសេដ្ឋកិច្ចផ្សេងទៀតមួយចំនួន » ។ ពាក់ព័ន្ធនឹងលិខិតនេះ ខ្ញុំសូមគោរពរាយការណ៍ជូន សម្តេចប្រធានរដ្ឋសភា ដូចតទៅ:

## I. សេចក្តីផ្តើម

1. តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមសម្តេចប្រធានមេត្តាអនុញ្ញាតឱ្យខ្ញុំ ឆ្លើយទៅនិងសំណួររបស់តំណាងរាស្ត្រ សុន ឆ័យ ជាលាយលក្ខណ៍អក្សរ ដោយមិនបាច់បង្ហាញមុខចំពោះរដ្ឋសភា ។ តាមផ្លូវច្បាប់ សំណើប្រកាន់ជំរើសរបៀបនេះ ស្របតាមរដ្ឋធម្មនុញ្ញទាំងស្រុង ។ យ៉ាងណាមិញ បទប្បញ្ញត្តិនៃមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញបានចែងថា « ចម្លើយរបស់រដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬ សរសេរជាលាយលក្ខណ៍អក្សរ » ។

2. មួយវិញទៀតបើពិនិត្យទិដ្ឋភាពនយោបាយ តំណាងរាស្ត្រ សុន ឆ័យ មិនមែនស្វែងរកគណនេយ្យភាពរបស់រាជរដ្ឋាភិបាល ចំពោះស្ថាប័ននីតិប្បញ្ញត្តិទេ ។ ជាការច្បាស់ក្រឡែត បំណងពិតនៃលិខិតលេខ

ស.ឆ ៤-00២/0៩ រ.ស ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២00៩ របស់តំណាងរាស្ត្រ សុន ឆ័យ គឺចង់បង្កអរិភាព ចំពោះរាជរដ្ឋាភិបាលប៉ុណ្ណោះ ។ លិខិតរបស់តំណាងរាស្ត្រខាងលើនេះ ពុំទាន់ទាំងឆ្លងការយល់ព្រមរបស់សម្តេចប្រធានរដ្ឋសភាផង ម្ចាស់លិខិតបានប្រកូកប្រកាសខ្លឹមសារនៃលិខិតរបស់ខ្លួនជាមុន ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២00៩ រួចទៅហើយ ។

3. សំណើររបស់ខ្ញុំ សូមឆ្លើយជាលាយលក្ខណ៍អក្សរ បានទទួលការយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី 0២ ខែ កុម្ភៈ ឆ្នាំ ២00៩ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល មិនដែល គេចវេសអំពីគណនេយ្យភាពរបស់ខ្លួនចំពោះស្ថាប័ននីតិប្បញ្ញត្តិទេ ។ ប្រវត្តិនៃនីតិកាលទី៤ នៃរដ្ឋសភា បានបង្ហាញតំណាងរាស្ត្រមកពីគណបក្សខ្លះ ពុំអាចបំពេញតួនាទីរបស់ខ្លួនឱ្យបានពេញលេញជាតំណាងរាស្ត្រ ។ នោះមិនមែនជាកំហុសអ្នកណាក្រៅពីយុទ្ធសាស្ត្រពហិការរបស់ខ្លួន ដោយផាត់ខ្លួនឯងចេញពីកិច្ចដំណើរការប្រក្រតី នៃយន្តការប្រជាធិបតេយ្យ សេរី ពហុបក្ស នៃព្រះរាជាណាចក្រកម្ពុជា ។ រូបភាពនៃពហិកានេះប្រៀបដូចជាអ្នកផ្តើមគំនិតពហិកា យករណារអារមែកឈើ ដែលខ្លួនកំពុងអង្គុយលើ ទម្លាក់ទាំងមែកឈើទាំងអាត្មា អ្នកអង្គុយលើមែកឈើមកលើដីដូច្នេះអញ្ចឹង ។

**II. ចំណាត់ថ្នាក់រាជរដ្ឋាភិបាលចំពោះសភាពការណ៍សេដ្ឋកិច្ចសកលលោកបច្ចុប្បន្ន**

4. ដូចសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់មានប្រសាសន៍ រាជរដ្ឋាភិបាលបានចាត់ការហើយ ដើម្បីគ្រប់គ្រងផលវិបាកដ៏អាក្រក់ នៃខិនភាពសេដ្ឋកិច្ចសាកលលោកមកលើ សេដ្ឋកិច្ចកម្ពុជា គឺបានចាត់ការមុនតំណាងរាស្ត្រ ម្ចាស់សំណួរបានលើក ។ ចំណាត់ការនេះនឹងបន្តទៀតជាខ្សែសង្វាក់ ។

5. សេដ្ឋកិច្ចសាកលលោក បច្ចុប្បន្ន ចុះដុនដាបមែនទែន ។ ការព្យាករណ៍ចុងក្រោយតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ( IMF ) នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២00៩ តាមរយៈការវិភាគរបស់លោក Olivier Blanchard ឧត្តមសេដ្ឋកិច្ចវិទូរបស់ខ្លួន ហើយដែលទទួលការប្រចាប់ត្រាផងដែរពីនាយកគ្រប់គ្រង Dominique Strauss-Kahn កំណើនសេដ្ឋកិច្ចសាកលលោកនឹងស្រុតចុះមកត្រឹម 0,៥ % នៅឆ្នាំ ២00៩ នេះ។ នេះជាកំណើនសេដ្ឋកិច្ចទាបបំផុតក្នុងរយៈពេល ៦0 ឆ្នាំចុងក្រោយនេះ ។ ទាំងនាយកគ្រប់គ្រង IMF Dominique Strauss-Kahn ទាំងប្រធានធនាគារពិភពលោក ( World Bank-WB) Robert B. Zoellick សុទ្ធតែបានលើកវិធានការដើម្បីស្រោចស្រង់សភាពការណ៍ ។ ប៉ុន្តែនៅវេទិកាសេដ្ឋកិច្ចពិភពលោក ( World Economic Forum ) នាទីក្រុង Davos នៅថ្ងៃទី ៣0 ខែ មករា ឆ្នាំ ២00៩ លោក Gordon Brown នាយករដ្ឋមន្ត្រីនៃចក្រភពអង់គ្លេសបានបញ្ចេញមតិថាទាំង IMF ទាំង WB កំពុងអស់ល័ក្ខណ៍ហើយ!

6. និយាយអំពីសាវតារសង្ខេប ដូចជ្រាបស្រាប់ ខិនភាពសេដ្ឋកិច្ចបច្ចុប្បន្នកើតចេញពីៈ

- វិបត្តិអចលនទ្រព្យនៃវិបត្តិឥណទាននិក្ខេប (Mortgage Loan Crisis ) នៃសហរដ្ឋអាមេរិក ។ វិបត្តិទាំងនេះនាំអោយកើត

- ការរាំងស្ទួតឥណទាន ដែលនាំឱ្យកើតជាវិបត្តិធនាគារ ហើយវិបត្តិនេះបណ្តាលឱ្យកើតជាវិបត្តិកលិយុគនៃហិរញ្ញវត្ថុអន្តរជាតិសាកលលោកតែម្តង ។ សូមគូសបញ្ជាក់ពាក្យ វិបត្តិកលិយុគ ។

ទន្ទឹមនឹងនេះ ក៏កើតអតិផរណា ។ ថ្លៃវត្ថុធាតុដើមឡើងថ្លៃទាំងអស់យ៉ាងគំហុកពីចុងឆ្នាំ ២០០៧ ។ និយាយតែប្រេងឆៅមួយមុខ ឡើងដល់ ១៤៧ ដុល្លារក្នុងមួយធុង នៅពាក់កណ្តាលឆ្នាំ ២០០៨ កន្លងទៅ គឺឡើង ៩០,៤% ធៀបប្រៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០០៧ ។ វិបត្តិកលិយុគ នៃហិរញ្ញវត្ថុអន្តរជាតិ នាំឱ្យ

- សេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ មានលក្ខណៈជាឱនភាពនៅគ្រប់កន្លែងទាំងអស់ ពិសេសសេដ្ឋកិច្ចសហរដ្ឋអាមេរិក និង អ៊ឺរ៉ុប ។ និយាយជារួមគ្មាន ទ្វីបណាមួយ ប្រទេសណាមួយគេចផុតពីព្យុះសង្ឃរានេះឡើយ ។

7. កម្ពុជាក៏រងគ្រោះ ពិសេសវាប៉ះពាល់វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យអចលនទ្រព្យ និងសំណង់ ។ ចំណែកផលប៉ះពាល់ចំពោះវិស័យកសិកម្ម ក៏មានប៉ះពាល់ដែរ ពិសេសថ្លៃម្ហូបអាហារ នៅតាមទីក្រុង និងថ្លៃធាតុចូលជាជី ប្រេងឥន្ធនៈ សំរាប់កសិកម្ម ។ ប៉ុន្តែជារួម កសិកររីករាយចំពោះតម្លៃកសិផលរបស់ខ្លួនដែលបានឡើង ។ ដោយកម្ពុជាស្ថិតក្នុងចរន្តសាកលភាវូបនីយកម្មសេដ្ឋកិច្ច ផលប៉ះពាល់នេះដល់សេដ្ឋកិច្ចមានលក្ខណៈ ធ្ងន់ធ្ងរ តែវាមិនធ្លាក់ដល់មានវិបត្តិ ។ ផលប៉ះពាល់នេះវានឹងអូសបន្លាយក្នុងរយៈពេលយូរ ឬឆាប់អាស្រ័យលើកត្តាក្រៅប្រទេស។ ពេលសេដ្ឋកិច្ចសាកលលោកងើបឡើងវិញ សេដ្ឋកិច្ចកម្ពុជានឹងងើបឡើងវិញដែរ ។ ប៉ុន្តែ ការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល មានលក្ខណៈសកម្មគ្រប់គ្រង ( proactif ) និងប្រទាក់ក្រឡាគ្នា តាមរយៈពិពិធកម្ម សេដ្ឋកិច្ចតាំងពីរាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ( យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១) ដោយរួមជាមួយតួអង្គនៃការអភិវឌ្ឍន៍ និងកំណែទំរង់ទាំងអស់ ក្នុងចលនាការនៃប្រព័ន្ធតួអង្គ និង ដោយយកគោលដៅឧត្តមភាពប្រកួតប្រជែងជាត្រីមុខ ក្នុងនេះមាន:

- ការបង្កើនផលិតភាពនិងការជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម និង ការបន្តការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ រូបវន្តសំរាប់ទ្រទ្រង់កំណើន
- ការអន្តរាគមន៍តាមវិស័យ ពិសេសវិស័យកាត់ដេរ និងទេសចរណ៍
- ការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជោគជ័យនៃវេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា ( CDCF ) លើកទី២ នាថ្ងៃទី៤-៥ ខែ ធ្នូ ឆ្នាំ ២០០៨ ជាភស្តុតាង
- ការពង្រឹងស្ថាប័ន និងការគ្រប់គ្រងធនធានមនុស្ស រាប់ទាំងការកសាងសមត្ថភាពសំរាប់បង្កើនផលិតភាព ។

រាជរដ្ឋាភិបាលជឿជាក់ថា វិធានការនឹងមិនធ្វើឱ្យសភាពការណ៍សេដ្ឋកិច្ចកម្ពុជា ធ្លាក់ក្នុងវដ្តសង្ឃារឱនភាពអាក្រក់នោះឡើយ ។

**III. វិធានការនានារបស់រាជរដ្ឋាភិបាល**

8. ចំណាត់ការរបស់រាជរដ្ឋាភិបាល ស្ថិតនៅក្នុងកញ្ចប់នៃការអនុវត្ត « យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ » របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាផង ។

វាមានលក្ខណៈជាប្រព័ន្ធផង ។ វាមានលក្ខណៈជានិរន្តភាពការងារផង ។ចំណាត់ការរបស់រាជរដ្ឋាភិបាលមានលក្ខណៈពហុទ្រង់ទ្រាយ ( multidimensional ) លក្ខណៈ សកម្មគ្រប់គ្រង ( proactif ) និងលក្ខណៈរស់រវើក ជាចលនាការ (dynamique) ។ វាមិនសំដៅទប់ទល់សភាពការណ៍ប៉ុណ្ណោះទេ ប៉ុន្តែវាមានលក្ខណៈជាការវាយសំរុកទៀត ក្នុងន័យកសាងឧត្តមភាពធៀបប្រៀបរបស់កម្ពុជាទៀតផង ។

### III. 1. វិធានការសំរាប់អនុវត្តគោលនយោបាយរូបិយវត្ថុ ( Monetary Policies ) និងសំរាប់គ្រប់គ្រងហិរញ្ញវត្ថុឯកជន

9. ដើម្បីទប់ទល់សម្ពាធអតិផរណា ដែលបានងើបក្បាលឡើងពីចុងឆ្នាំ ២០០៧ នៅខែមេសា ឆ្នាំ ២០០៨ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការប្រុងប្រយ័ត្នចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរួមមានៈ

- ការតម្លើងអាត្រាទុនបំរុងកាតព្វកិច្ចពី ៨% ដល់ ១៦% ចំពោះប្រាក់បញ្ញើជារូបិយប័ណ្ណ
- ការកំណត់កំរិតពិតានឥណទានចំនួន ១៥% ចំពោះវិស័យអចលនទ្រព្យ ។

ធ្វើយ៉ាងនេះ គឺដើម្បីកាត់បន្ថយល្បឿនឥណទានចំពោះវិស័យមិនមែនផលិតកម្ម ។ វិធានការនេះរួមចំណែកគ្រប់គ្រងអតិផរណាបានមួយកំរិតធំ ។

10. ក្នុងបរិការណ៍មួយ ដែលឱនភាពសេដ្ឋកិច្ចសាកលលោកជះឥទ្ធិពលកាន់តែអាក្រក់ដល់សេដ្ឋកិច្ចកម្ពុជា ហើយសម្ពាធអតិផរណាបានថមថយ រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិនៃកម្ពុជា បានយកវិធានការនៅក្នុងខែមករា ឆ្នាំ ២០០៩ ដូចតទៅៈ

- បន្ថយអត្រាទុនបំរុងកាតព្វកិច្ចពី ១៦% មក ១២% ចំពោះប្រាក់បញ្ញើជារូបិយប័ណ្ណហើយជំរុញឥណទានដល់វិស័យផលិតកម្ម និងកសិកម្ម ។
- លុបចោលការកំណត់ពិតានចំនួន ១៥% ចំពោះអចលនទ្រព្យ ហើយណែនាំធនាគារអោយពង្រឹងការគ្រប់គ្រងហានិភ័យនៃវិស័យអចលនទ្រព្យអោយបានត្រឹមត្រូវ ។

11. រាជរដ្ឋាភិបាលបន្តរក្សាអប្បមាទខ្ពស់ ចំពោះការអភិវឌ្ឍន៍វិស័យធនាគារ ដើម្បីរក្សាជំនឿលើវិស័យនេះ។ ធនាគារជាតិនៃកម្ពុជា បានពង្រឹង និងពង្រីកយន្តការតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ មានក្រុមហ៊ុនធានារ៉ាប់រងជាដើម ។

12. ជាលទ្ធផល ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ ដែលមានការថយចុះខ្លាំងក្នុងអំឡុងខែ កក្កដា ឆ្នាំ ២០០៨ បានប្រកបលក្ខណៈល្អប្រសើរឡើងវិញ ចាប់ពី ខែសីហា ខែធ្នូ ឆ្នាំ ២០០៨ ។ ទុនបំរុងអន្តរជាតិបានកើនដល់ជាង ២,១០០ លានដុល្លារអាមេរិក ធានាបានការនាំចូល ៣,៨ខែ ។ ខាងផ្នែកធានារ៉ាប់រងពិតមែនតែទីផ្សារចង្អៀត មានការរីកចំរើនខាងចំណូល ហើយក៏មានការបង្កើតក្រុមហ៊ុនថ្មីថែមទៀតបន្ទាប់ពីរាជរដ្ឋាភិបាលបានសំរេចដោយជោគជ័យនូវឯកជនភាវូបនីយកម្មក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ។

### III. 2. វិធានការតាមរយៈអន្តរាគមន៍ នៃហិរញ្ញវត្ថុសាធារណៈ

### III. 2.1 វិធានការសំរាប់សំរាលផលប៉ះពាល់នៃអតិផរណា មកលើមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ

- ក្នុងឆ្នាំ ២០០៨ ពេលទំនិញឡើងថ្លៃគំហុក រាជរដ្ឋាភិបាលបានយកវិធានការ ជួយសំរាលផលប៉ះពាល់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ដោយ

. បន្តតម្លើងបៀវត្សមូលដ្ឋាន ២០%

. តម្លើងប្រាក់បំណាច់មុខងារបង្រៀនចំនួន ១០% ជូនគ្រូបង្រៀន

. ឧបត្ថម្ភជីវភាពម្នាក់ ២០ ០០០ រៀលក្នុងមួយខែ ពីខែកក្កដា ដល់ខែ ធ្នូ ឆ្នាំ ២០០៨

. យកវិធានការសម្រួលបៀវត្ស និងប្រាក់បំណាច់មុខងារជូនកងកំលាំងប្រដាប់អាវុធ ។

កញ្ចប់ថវិកាប្រភេទចំណាយបៀវត្សឡើងពីមួយខែ ៨២ ពាន់លានរៀលនៅឆ្នាំ ២០០៧ ជាមធ្យមដល់ ១០០ ពាន់លានរៀលនៅត្រីមាសទី៤ នៃឆ្នាំ ២០០៨ ។

- ក្នុងឆ្នាំ ២០០៩ រាជរដ្ឋាភិបាលបន្តយកវិធានការៈ

. បន្តតម្លើងបៀវត្សមូលដ្ឋាន ២០%

. បន្តអនុវត្តវិធានការផ្តល់ប្រាកបំណាច់មុខងារជូនកងកំលាំងប្រដាប់អាវុធ ។

កញ្ចប់ថវិកាសរុបនៃប្រភេទបៀវត្ស នឹងអាចឡើងដល់ជាង ១២០ ពាន់លានរៀល ក្នុង១ខែ ។

ប៉ុន្តែ ទោះជាយ៉ាងណា រាជរដ្ឋាភិបាល ខិតខំរក្សាឱ្យវាស្ថិតនៅជាសរុបក្នុងរង្វង់ ៩% នៃ ផ.ស.ស ក្នុងក្របខ័ណ្ឌនៃការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។

### III. 2.2 វិធានការសំរាប់អនុវត្តគោលនយោបាយពន្ធ និងអាករ សំរាប់ផ្នែកឯកជន

13. វិធានការសំរាប់អនុវត្តគោលនយោបាយថវិកា សុទ្ធតែស្ថិតក្នុងច្បាប់និងលិខិតបទដ្ឋាន នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគយ ។ល។ មានន័យថា ក្នុងកំណែទំរង់ និងក្នុងការអភិវឌ្ឍន៍ រាជរដ្ឋាភិបាល ម៉្យាងមានកិច្ចដំណើរការជាប្រព័ន្ធផង និង ស្របច្បាប់ផង ។ វិធានការនេះ មានលក្ខណៈ បង្ការជាមុន ។ ធ្វើយ៉ាងនេះបានដោយសារលទ្ធផលជាវិជ្ជមានកើតចេញ ពីការដ្ឋានកំណែទំរង់នានាដែលកសាងបាននូវប្រព័ន្ធកាន់តែសុក្រឹត្យភាព និងបង្កើនបាននូវអភិបាលកិច្ច កាន់តែល្អ។

14. ដើម្បីទប់ទល់ថ្លៃទំនិញយុទ្ធសាស្រ្ត គឺប្រេងឥន្ធនៈ សំរាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងសុខមាលភាពរបស់ប្រជាជន រាជរដ្ឋាភិបាលបានឧបត្ថម្ភធនដោយស្ងាត់ស្ងៀមចំនួនសមមូលប្រមាណជិត ៣០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៨ ដើម្បីកំរិតមូលដ្ឋានទាញពន្ធមួយឥតមានប្រែប្រួលពីឆ្នាំ ២០០៤ មក ។ បើគេចង់ដឹងថា តើវិធានការណ៍នេះ បានផ្តល់ប្រយោជន៍យ៉ាងណាដល់កំណើនសេដ្ឋកិច្ច និងសុខមាលភាពប្រជាជន គេត្រូវធៀបប្រៀបបំរែបំរួលតម្លៃប្រេងនៅលើឆាកអន្តរជាតិ និងតម្លៃប្រេងសាំងចែកចាយតាមស្ថានីយ៍។ ឃើញថា នៅខែ កក្កដា ឆ្នាំ ២០០៨ ពេលប្រេងនៅឡើងថ្លៃ ៩០,៤% ធៀបប្រៀបនឹងថ្លៃនៅខែ កក្កដា ឆ្នាំ ២០០៧ ថ្លៃប្រេងសាំងតាមស្ថានីយ៍ឡើងតែ

៤២,៣% ប៉ុណ្ណោះ ធៀបប្រៀបនឹងរយៈពេលដូចគ្នា ។ នៅក្នុងឆ្នាំ ២០០៩ ទោះបីតម្លៃប្រេងឆៅបច្ចុប្បន្នលើផ្សារអន្តរជាតិចុះក៏ដោយ ក៏រាជរដ្ឋាភិបាល នៅបន្តវិធានការឧបត្ថម្ភធនប្រមាណ ៧ លានដុល្លារ អាមេរិកក្នុងមួយខែៗ ។

15. ក្នុងឆ្នាំ ២០០៨ ពន្ធ និងអាករលើទំនិញនាំចូល ដែលរដ្ឋទទួលបន្ទុកសំរាប់ទ្រទ្រង់វិនិយោគទាំងកម្មន្តសាល ទាំងហេដ្ឋារចនាសម្ព័ន្ធ មានចំនួនសមមូលប្រមាណជាង ៤៩០ លានដុល្លារអាមេរិក ។ លើសពីនេះ ចំពោះសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបំរើអោយការនាំចេញ ចាប់ពីឆ្នាំ ២០០៥ មក ត្រូវបានផ្តល់ការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណេញបន្តរយៈពេល ០២ ឆ្នាំ ហើយការបន្តរយៈពេលលើកលែងពន្ធនេះ រដ្ឋបានធ្វើសម្បទានថវិកា សមមូលនឹងចំនួនប្រមាណពី ១៨ លាន ទៅ ២៩ លានដុល្លារអាមេរិក ។ បន្ថែមពីលើការលើកទឹកចិត្តនេះ រាជរដ្ឋាភិបាល បានអនុញ្ញាត្តិអោយឧស្សាហកម្មគាំទ្រ ឬ អ្នកចុះកិច្ចសន្យាចំនួន ៤០ សហគ្រាស អនុវត្តអត្រាអាករលើតម្លៃបន្ថែម 0% ចំពោះការផ្គត់ផ្គង់ផលិតផល ឬ សេវាសំរាប់បំរើ អោយការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ដែលធ្វើអោយរដ្ឋបាត់លំហូរសាច់ប្រាក់សមមូលនឹងចំនួនប្រមាណ ១៣ លាន ដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៨ ។ ចាប់ពីឆ្នាំ ២០០៧ មកដើម្បីសំរួលដល់ចលនាសាច់ប្រាក់របស់សហគ្រាសកាត់ដេរនាំចេញ រាជរដ្ឋាភិបាល បានលើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែ ដោយរង់ចាំឱ្យសហគ្រាសបង់ពន្ធលើប្រាក់ចំណេញនៅដំណាច់ឆ្នាំជំនួសវិញ ហើយការលើកលែងការបង់ប្រាក់រំដោះពន្ធលើ ប្រាក់ចំណេញប្រចាំខែនេះ ធ្វើឱ្យរដ្ឋបាត់លំហូរសាច់ប្រាក់សមមូលនឹងចំនួនប្រមាណ ១៣ លានដុល្លារអាមេរិកក្នុង ឆ្នាំ២០០៨ ។ ការទទួលបន្ទុក និងសម្បទានេះ និងបន្តទៀតក្នុងឆ្នាំ ២០០៩ ដើម្បីទ្រទ្រង់វិស័យទាំងពីរនេះ តាមការ គណនា មានចំនួនសមមូលនឹងប្រមាណ ៥០០លានដុល្លារអាមេរិក ។

16. សំរាប់ជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យមៈ ទឹកប្រាក់ពន្ធ និងអាករនាំចូល សមមូលនឹងចំនួនប្រមាណជាង ៥លាន ដុល្លារអាមេរិក ត្រូវបានកាត់បន្ថយតាមរយៈការបន្ថយអត្រាពន្ធគយលើមុខទំនិញជាវត្ថុធាតុដើម និង មធ្យោបាយផលិតកម្មដែលរួមមានជាពិសេស សារធាតុគីមី វត្ថុធាតុដើម ជាលោហធាតុ ដែលស្ថិតក្នុងទំរង់បឋមតាមរូបភាពមិនទាន់កែច្នៃ ឬជាដុំ ជាម្សៅ ជាគ្រាប់ និងជាសន្លឹក ប្រៀបធៀបទិន្ន័យឆ្នាំ ២០០៧ ។ ផលិតផលក្នុងស្រុកដែលបានជំនួសផលិតផលនាំចូលនាពេលបច្ចុប្បន្ន រួមមានជាអាទិ៍ ភេសជ្ជៈ ( ស្រាបៀរ ទឹកក្រូច ទឹកផ្លែឈើ ) គ្រឿងឧបភោគបរិភោគផ្សេងៗ ( បារី មីកញ្ចប់ នំ ស្បៀងអាហារ ) សំភារៈបរិក្ខារសាងសង់ ( ស៊ីម៉ង់ត៍ ថ្នាំលាប បរិក្ខារអគ្គីសនី បរិក្ខារទឹក គ្រឿងសង្ហារឹមបំពាក់ ) ព្រមទាំងផលិតផល ប្លាស្ទិក និងក្រដាស ( សំបកវេចខ្ចប់ សំបកកំប៉ុងភេសជ្ជៈ សំភារៈប្រើប្រាស់ក្នុងលំនៅដ្ឋាន ) ជាដើម ។

17. សំរាប់វិស័យជំរុញកសិកម្មៈ ទឹកប្រាក់ពន្ធ និងអាករនាំចូលសមមូលនឹងចំនួនប្រមាណ ៨ លានដុល្លារ អាមេរិក ត្រូវបានកាត់បន្ថយតាមរយៈការបន្ថយពន្ធគយ មកសូន្យភាគរយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋលើវត្ថុធាតុដើម និង មធ្យោបាយផលិតកម្មកសិកម្មនានារួមមាន ជាពិសេសពូជសត្វ ពូជដំណាំ ចំណីសត្វ ជីកសិកម្ម វត្ថុធាតុដើមផលិតចំណីសត្វ ម៉ាស៊ីនបូមទឹក ត្រាក់ទ័រកសិកម្ម ព្រទាំងមុខទំនិញជាសំភារៈ និងម៉ាស៊ីនកសិកម្មផ្សេងទៀត ។

### III. 2.2 វិធានការខាងគោលនយោបាយថវិកា មានលក្ខណៈទាក់ទងនឹងម៉ាក្រូសេដ្ឋកិច្ច

18. វិធានការដោយឡែកៗ ខាងពន្ធ និងអាករ ដូចបានរៀបរាប់ខាងលើ សំដៅទ្រទ្រង់សកម្មភាពនៃផ្នែកខ្លះនៃវិស័យឯកជន ។ សំរាប់វិស័យឯកជនទូទៅ ដើម្បីប៉ះប៉ូវទៅតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទប់ទល់ការស្រុតចុះនៃសកម្មភាពវិនិយោគឯកជន រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវកញ្ចប់គោលនយោបាយថវិកាមួយ ដែលមានលក្ខណៈគាំទ្រ និង ជំរុញកំណើន ក្នុងល័ក្ខខ័ណ្ឌដែលមិនបង្កផលអវិជ្ជមានដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ពិសេសគឺការគ្រប់គ្រងឱ្យបាននូវអតិផរណា ព្រមទាំងត្រូវខិតខំកៀរគរយកមកប្រើឱ្យអស់លទ្ធភាព និងអោយបានប្រកបដោយប្រសិទ្ធភាព នូវប្រភពហិរញ្ញប្បទានសហប្រតិបត្តិការពីសំណាក់ដៃគូអភិវឌ្ឍទាំងឡាយរបស់ខ្លួន ។ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់អំពីតម្រូវការនេះ ហើយបាន និង កំពុងដាក់ចេញជាបន្តបន្ទាប់នូវវិធានការគោលនយោបាយចាំបាច់ ទាំងឡាយ ដើម្បីគោលដៅនេះ ដែលមានលក្ខណៈជា expansionary ។ ជាក់ស្តែង បើគេវិភាគកញ្ចក់ថវិកាជាតិសម្រាប់ឆ្នាំ ២០០៩ ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៩ គេនឹងឃើញថា កញ្ចប់ថវិកាដែលមានលក្ខណៈគាំទ្រ និង ជំរុញកំណើន ដោយក្នុងនោះរាជរដ្ឋាភិបាល បានរៀបចំឱ្យមានឱនភាពទូទៅនៃថវិកាជាតិដោយមិនគិតហិរញ្ញប្បទានឥតសំណង ក្នុងទំហំជាទឹកប្រាក់សមមូល ជាង ៥០០ លានដុល្លារអាមេរិកឬត្រូវជាប្រមាណ ៣,២% នៃ ផសស ។ ក្នុងឆ្នាំ ២០០៨ ឱនភាពទូទៅក្នុងការអនុវត្តថវិកាជាតិ ដោយមិនគិត ហិរញ្ញប្បទាន ឥតសំណងក្នុងទំហំជាទឹកប្រាក់សមមូលតែប្រមាណជាង ១៧០ លានដុល្លារអាមេរិក ឬត្រូវជា ប្រមាណ ១,៧% នៃ ផសស ប៉ុណ្ណោះ ។ នេះគឺជាការរៀបចំដោយមានការគិតគូរ ថ្លឹងថ្លែងម៉ត់ចត់ត្រឹមត្រូវរវាងម្ខាង ជាសេចក្តីត្រូវការក្នុងការគាំទ្រនិងជំរុញកំណើន ដែលជាគោលនិយោបាយ expansionary និងម្ខាងទៀតជាសេចក្តីត្រូវការ និងលទ្ធភាពក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលផ្ទុយពីអ្នកនយោបាយមួយចំនួនដែលចេះតែប្រកាសអំពាវនាវឱ្យរៀបចំកញ្ចប់ថវិកា ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ជាឧទាហរណ៍ ក្នុងទំហំ ៥០០ លានដុល្លារអាមេរិកដែលគេមិនដឹងថាតួលេខនេះ ចេញមកពីណា។

19. នៅក្នុងគោលនិយោបាយចំណាយថវិកាសម្រាប់ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលបន្តផ្តោតអាទិភាពជាសំខាន់ទៅលើការបង្កើនទុនវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានប្រព័ន្ធគមនាគមន៍ ដឹកជញ្ជូន ប្រព័ន្ធធារាសាស្ត្រ និងការបង្កើតផលិតភាពកសិកម្ម ដើម្បីកាត់បន្ថយថ្លៃដើមនៃការផលិត និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមមួយចំនួន ។ ទោះជាយ៉ាងនេះហើយក៏ដោយ រាជរដ្ឋាភិបាលនៅតែមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងការតាមដានការអនុវត្តថវិកាជាតិ ទាំងផ្នែកចំណូល និងចំណាយ ។ ជាការពិត រាជរដ្ឋាភិបាលនៅតែមានការព្រួយបារម្ភមួយចំនួនថែមទៀត ចំពោះលទ្ធភាពធ្លាក់ចុះខ្លះៗ នៃចំណូលរដ្ឋ ដោយសារការស្រកស្រុតនៃសកម្មភាព សេដ្ឋកិច្ច និងសកម្មភាពនីហរ័ណ-អាហរ័ណ រួមជាមួយលទ្ធភាពនៃការកើតមានឡើងនូវសេចក្តីត្រូវការថ្មីមួយ ចំនួនផ្សេងទៀត ខាងផ្នែកចំណាយ ពិសេសសេចក្តីត្រូវការក្នុងវិស័យហេដ្ឋារចនាសម្ព័នរូបវន្ត ការបង្កើតផលិតភាព និងប្រព័ន្ធសុវត្ថិភាពសង្គម ។

20. ដូច្នេះ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល ដាក់ចេញនូវវិធានការមួយចំនួនថែមទៀតដូចខាងក្រោម ៖

1. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រប់ក្រសួង-ស្ថាប័ននេះពាក់ព័ន្ធ បន្តជំរុញកៀរគរ ប្រមូលចំណូលគ្រប់ប្រភេទ ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ប្រកបដោយប្រសិទ្ធភាពឱ្យបានគ្រប់តាមដៅដែល មានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង ឆ្នាំ ២០០៩ ។
2. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំត្រួតពិនិត្យឡើងវិញនូវកញ្ចប់ចំណាយថវិកាជាតិដើម្បីធ្វើវិចារណកម្មចំណាយចរន្ត ដែលមិនមានភាពចំបាច់ ឬមិនទាន់ចាំបាច់ ហើយបង្វែរកញ្ចប់ថវិកាដែលបាលពីការធ្វើ វិចារណកម្មចំណាយនេះមកសន្សំទុកសម្រាប់ចំណាយទៅលើ សកម្មភាពដែលគាំទ្រដល់ការទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយផ្ទាល់ និងសម្រាប់ចំណាយ អន្តរាគមន៍របស់រដ្ឋលើវិស័យសុវត្ថិភាពសង្គម និង លើការដោះស្រាយផលប៉ះពាល់ជាយថាហេតុ ដែលកើតពីវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលលោកនេះ ។
3. វិធានការជាក់ស្តែងក្នុងការធ្វើវិចារណកម្មចំណាយ ដែលត្រូវជំរុញអនុវត្តបន្ទាន់ គឺការសន្សំ ចំណាយលើប្រេងឥន្ធនៈរបស់ក្រសួង-ស្ថាប័ន ដែលបច្ចុប្បន្ននេះ ថ្លៃប្រេងឥន្ធនៈបានធ្លាក់ចុះយ៉ាងច្រើនហើយ បើធៀបទៅនឹង ថ្លៃប្រេងឥន្ធនៈនៅពេលយើងគិតគូររៀបចំកញ្ចប់ ចំណាយកាលពីឆ្នាំកន្លងទៅ ។

### III.3 គោលនយោបាយទាក់ទាញ និង ប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ:

21. សម្រាប់ឆ្នាំ ២០០៩ នេះ នៅក្នុងកិច្ចប្រជុំនៃ «វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជា លើកទី ២ » រាជរដ្ឋាភិបាលកៀរគរបាននូវក្របខ័ណ្ឌ ហិរញ្ញប្បទានសហប្រតិបត្តិការ ប្រមាណ ១ ពាន់លានដុល្លារអាមេរិក ដែលជាលទ្ធផលខ្ពស់បំផុត ធៀបទៅនឹងលទ្ធផលនៃការខិតខំកៀរគរ ធនធានហិរញ្ញប្បទានអភិវឌ្ឍន៍ពីសំណាក់ដៃគូអភិវឌ្ឍផ្លូវការទាំងឡាយនៅក្នុង រយៈពេលជិត ១០ ឆ្នាំចុងក្រោយនេះ ។ ជាការពិត នៅក្នុងបរិការណ៍បច្ចុប្បន្ន ហិរញ្ញប្បទានសហប្រតិបត្តិការនេះ គឺជាជន្ទល់មួយដ៏សំខាន់ក្នុងការ ជួយកាត់បន្ថយផលប៉ះពាល់ ដែលកម្ពុជាកំពុងទទួលរងពីកលិយុគនៃវិបត្តិហិរញ្ញវត្ថុ និង ឱនភាពសេដ្ឋកិច្ច ជាសកលនេះ ។ ដូច្នេះ រាជរដ្ឋាភិបាល ខិត ខំទាក់ទាញ និង ប្រើប្រាស់ហិរញ្ញប្បទាន សហប្រតិបត្តិការ អភិវឌ្ឍន៍ផ្លូវការនេះ ឱ្យចំទិសដៅ និង ប្រកបដោយ ប្រសិទ្ធភាពខ្ពស់ ។ រាជរដ្ឋាភិបាលខិតខំអនុវត្តការងារ មួយចំនួនដូចតទៅ៖

1. ជំរុញ «ការផ្ទេរធនធានសុទ្ធ» ឱ្យបានច្រើនដល់កម្ពុជា ដើម្បីគោលដៅនៃការវិនិយោគ និងការបង្កើតផលិតផលភាពនៃសេដ្ឋកិច្ចជាតិ ដែលប្រការនេះនឹងផ្តល់ផលវិជ្ជមានយ៉ាងច្រើនដោយត្រង់ និង ភ្លាមៗ ចំពោះការខិតខំជំរុញកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រ របស់ប្រជាជន ។
2. ជំរុញបង្កើនល្បឿននៃការអនុវត្តគម្រោង ឱ្យបានប្រកបដោយប្រសិទ្ធភាព និង ក្នុងស្មារតីនៃការទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងទិសដៅទាក់ទាញការបើកផ្តល់ធនធានហិរញ្ញវត្ថុមកក្នុងប្រព័ន្ធសេដ្ឋកិច្ចឱ្យបានឆាប់ និងបានច្រើន ក្នុងពេលចំពោះមុខផង និង ក្នុងទិសដៅបង្កើនសមត្ថភាពស្រូបរបស់កម្ពុជាទូទៅផង ។

22. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានខិតខំសម្របសម្រួលជាមួយនឹងគ្រប់ក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើនល្បឿននៃការអនុវត្តន៍វិធានការកែទម្រង់ចាំបាច់នានា ដែលជាល័ក្ខខ័ណ្ឌវិនិច្ឆ័យ សម្រាប់ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រថវិកា ក្នុងទិសដៅទាក់ទាញធនធាននេះ មកប្រើឱ្យបានឆាប់រហ័ស និង ប្រកបដោយប្រសិទ្ធភាព ។ ជាមួយគ្នានេះដែរ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានខិតខំសម្របសម្រួលការចរចាជាមួយដៃគូដែលមានការពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគំរោងសហប្រតិបត្តិការទាំងឡាយ និងដើម្បីទាក់ទាញយកមកប្រើប្រាស់នូវធនធានហិរញ្ញប្បទានសហប្រតិបត្តិការដ៏ទៃទៀត ដែលអាចបើកផ្តល់ និង អនុវត្តបានឆាប់នៅតាមវិស័យជាអាទិភាព របស់រាជរដ្ឋាភិបាល ។

### III.4 អន្តរាគមន៍តាមវិស័យ និងការពង្រឹង ពង្រីកសម្ថភាពធនធានមនុស្ស និង ស្ថាប័ន

23. វិធានការសំរាប់អនុវត្តគោលនយោបាយថវិកា និង ពន្ធនិងអាករ បានបង្ហាញអំពីអន្តរាគមន៍របស់រាជរដ្ឋាភិបាលសំរាប់គាំទ្រ ស្រោចស្រង់វិស័យកម្មន្តសាល និង សំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។ គេត្រូវតែទទួលស្គាល់ថា រាជរដ្ឋាភិបាលធ្វើសម្បទានខាងពន្ធ និងអាករ ជាអតិបរមាហើយក្នុងក្របខ័ណ្ឌច្បាប់ និង លិខិតបទដ្ឋានជាធរមាន សំរាប់វិស័យកម្មន្តសាល ។ និយាយពីវិធានការខាងគោលនយោបាយព និង អាករ ហាក់ដូចជារ៉ឺស័រអញ្ចឹង ។ បើនិយាយថា ទាញឱ្យវាយារ នោះវាយារអស់ហើយ ។ បើនិយាយថា រុញសង្កត់វិញ គឺវាលែងសំប៉ែតទៀតហើយ ។ នៅសល់តែវិធានការបួនទៀត ក្នុងក្របខ័ណ្ឌការងារសម្រួលធុរកិច្ច និងលំអបរិយាកាសវិនិយោគ ។ នោះគឺ:

. ការជំរុញវិស័យកិសិកម្ម ទាំងផលិតកម្ម ទាំងការកែច្នៃផលិតផល

. ការស្រោចស្រង់វិស័យកាត់ដេរ និង វិស័យទេសចរណ៍

. ការអនុវត្តចលនាការនៃប្រព័ន្ធតួអង្គ

. ការបន្តកំណែទំរង់រចនាសម្ព័ន្ធ ។

### III.4.1 ការជំរុញវិស័យកសិកម្ម ទាំងផលិតកម្ម ទាំងការកែច្នៃផលិតផល

24. វិធានការនេះ ស្ថិតក្នុងកញ្ចប់នៃការអភិវឌ្ឍន៍ជនបទ និង សេដ្ឋកិច្ចជនបទ និយាយរួមក្នុងក្របខ័ណ្ឌពិពិធកម្មសេដ្ឋកិច្ច នៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់ការទី២ ។ ក្រៅពីវិធានការខាងពន្ធ និងអាករ ដូចពោលខាងលើ សំរាប់វិស័យកសិកម្ម រាជរដ្ឋាភិបាល បានគិតដល់អំពីកត្តាតម្លៃផលិតកម្ម និង ថ្លៃផលិតផល ជាពិសេសការង្កើនសមត្ថភាពប្រមូលទិញស្តុក និង កែច្នៃស្រូវ-អង្ករសរបស់កម្ពុជា ។ ក្នុងគោលដៅនេះ កន្លងមក រាជរដ្ឋាភិបាល បានផ្តល់ហិរញ្ញប្បទាន ពិសេស តាមរយៈធនាគារអភិវឌ្ឍន៍ជនបទដល់រោងម៉ាស៊ីនកិនស្រូវឯកជន ដើម្បីទិញប្រមូលស្រូវ-អង្ករ ទុកសម្រាប់ធានាការផ្គត់ផ្គង់ក្នុងស្រុក ដែលនៅឆ្នាំ២០០៨ ទឹកប្រាក់នេះ មានចំនួនសមមូល ១២ លានដុល្លារ។ ក្នុងឆ្នាំ២០០៩ នេះរាជរដ្ឋាភិបាលបានចុះកិច្ចសន្យាបន្តកិច្ចការនេះ ជាមួយនឹងធនាគារអភិវឌ្ឍន៍ជនបទ តទៅទៀតក្នុងទំហំ

ទឹកប្រាក់រហូតដល់សមមូល ១៨ លានដុល្លារ ។ ឆ្លើយតបនឹងសភាពការណ៍ តម្រូវនាពេលបច្ចុប្បន្ន ក៏ដូចក្នុងគោលដៅធានានូវ និត្យានុកូលភាព និង ចីរភាពនៃការងារតទៅអនាគត រាជរដ្ឋាភិបាល នឹងរៀបចំនូវក្របខ័ណ្ឌគតិយុត្តដើម្បីប្រែក្លាយកញ្ចប់ថវិកានេះ ឱ្យទៅជា «មូលនិធិទ្រទ្រង់ និង អភិវឌ្ឍន៍ កសិកម្ម» ហើយប្រគល់ទៅអោយធនាគារអភិវឌ្ឍន៍ជនបទគ្រប់គ្រង ក្នុងរូបភាពជាកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល សំរាប់ជួយគាំទ្រដល់វិស័យឯកជន ពិសេសសហគ្រាសធុនតូច និងមធ្យម លើគោលដៅអាទិភាពមួយចំនួន រួមមានៈ

(១). ការផ្តល់ឥណទានសម្បទានរយៈពេលខ្លីសម្រាប់ការប្រមូលទិញស្រូវ-អង្ករពីកសិករក្នុងតម្លៃមួយសមរម្យ ក្នុងទិសដៅរក្សាស្ថិរភាពថ្លៃផង និង ធានាសន្តិសុខស្បៀងផង និង (២). ការផ្តល់ឥណទានសម្បទានរយៈពេលមធ្យមដល់ក្រុមហ៊ុនកែច្នៃស្រូវ-អង្ករ សំដៅពង្រីកសមត្ថភាពឃ្លាំងស្តុក ម៉ាស៊ីនសម្ងួត និង ម៉ាស៊ីនកែច្នៃ ។ រាជរដ្ឋាភិបាលកំពុងបន្តរៀបចំសម្រួលកាត់បន្ថយនិតិវិធីសម្រាប់ការនាំចេញអង្ករឱ្យបានជាអតិបរមា និង ពង្រឹងជាបណ្តើរៗនូវយន្តការគ្រប់គ្រងការនាំស្រូវចេញ ទន្ទឹមនឹងការខិតខំបង្កើនសមត្ថភាពក្នុងស្រុក ក្នុងការប្រមូលទិញ កែច្នៃ ចែកចាយ និង នាំចេញអង្ករ ។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលកំពុងតែរៀបចំនីតិវិធីច្បាប់ ដើម្បីដាក់បញ្ចូល គំរោងវិនិយោគក្នុងវិស័យកសិកម្ម ពិសេសគំរោងវិនិយោគលើការកែច្នៃផលិតផលកសិកម្ម មានជាអាទិ៍ គម្រោង វិនិយោគស្តុក និងកែច្នៃនាំចេញអង្ករឱ្យទៅជាគម្រោងអាទិភាព ដែលទទួលបាននូវការលើកទឹកចិត្តខ្ពស់នៅក្នុង ក្របខ័ណ្ឌនៃច្បាប់ស្តីពីវិនិយោគជាធរមាន ។ រាជរដ្ឋាភិបាលកំពុងតែជំរុញអោយមានភាពជាដៃគូរវាងកសិករ ម្ចាស់ដីតូចៗ និង កសិដ្ឋានខ្នាតធំសាជីវកម្មកសិកម្ម និងរវាងសម្បទានិកដីសេដ្ឋកិច្ច ជាមួយនឹងសម្បទានិកដីសង្គមកិច្ច ពិសេសជំរុញបង្កើតសហគមន៍កសិករ និង បង្កើតអោយមានភាពជាដៃគូរវាងសហគមន៍កសិករនេះ ជាមួយនិងក្រុមហ៊ុនប្រមូលទិញ កែច្នៃ ចែកចាយ និង នាំចេញផលិតផលស្រូវ-អង្ករ ។ គួបផ្សំនឹងវិធានការខាងលើនេះ រាជរដ្ឋាភិបាលបានអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីផ្តល់មូលនិធិបន្ថែមសម្រាប់គោលដៅនៃការលើកស្ទួយវិស័យកសិកម្ម ដែលជាវិស័យអាទិភាពដ៏ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នេះ ។

### III.4.2 ការស្រោចស្រង់វិស័យកាត់ដេរ និងវិស័យទេសចរណ៍

25. ដូចបានបរិយាយខាងលើ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់ អំពីបញ្ហាប្រឈមដែលវិស័យកាត់ដេរកំពុងតែជួបប្រទះដោយកត្តាក្រៅប្រទេស ។ កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ បន្តបន្ទាប់ ទាំងវិធានការខាងពន្ធនិងអាករ ទាំងវិធានការខាងការសម្រួលនីតិវិធីផ្សេងៗទៀតដើម្បីជួយគាំទ្រដល់ វិស័យកាត់ដេរ ។ ជាការពិត នៅក្នុងសភាពការណ៍បច្ចុប្បន្ន សមត្ថភាពខាងថវិកា និង សារពើពន្ធរបស់រាជរដ្ឋាភិបាល ត្រូវបានទាញបន្តឹងដល់កម្រិតអតិបរមាទៅហើយ ។ យ៉ាងណាក៏ដោយរាជរដ្ឋាភិបាលនៅតែមើល ឃើញនូវលទ្ធភាព និង ភាពចាំបាច់ក្នុងការជួយដោះស្រាយការលំបាកមួយចំនួនទៀត ពាក់ព័ន្ធនឹងការសម្រួលនីតិវិធី និង ការជួយកាត់បន្ថយឧបសគ្គ និងការលំបាកនានា ក្នុងការធ្វើពាណិជ្ជកម្ម ដែលអាចជួយសម្រួល ឬ ជួយកាត់បន្ថយថ្លៃដើមក្នុងការផលិត

និង ក្នុងការដឹកជញ្ជូន ការជួយរកប្រភពហិរញ្ញប្បទានសម្រាប់សកម្មភាពពាណិជ្ជកម្ម ការធ្វើពិពិធកម្មទីផ្សារ និង ការជួយសម្របសម្រួលរវាងនិយោជក និង កម្មករជាដើម ។

26. រាជរដ្ឋាភិបាលបានរំពឹងជាមុនថា ការបិទរោងចក្រកាត់ដេរមួយចំនួនដែលគ្មានប្រសិទ្ធភាពសេដ្ឋកិច្ច គ្មានសមត្ថភាពប្រកួតប្រជែងគ្រប់គ្រាន់ គឺជាបញ្ហាចៀសមិនផុត គ្រាន់តែជាការមុន ឬក្រោយប៉ុណ្ណោះ ។ ច្បាស់ណាស់ថា បញ្ហានេះអាចកើតឡើងកាន់តែច្រើន នៅក្នុងសភាពការណ៍លំបាកនាពេលបច្ចុប្បន្ន ។ ដូច្នេះ ការធានាឱ្យបានក្នុងកម្រិតអប្បបរមាណាមួយ ស្របតាមសមត្ថភាពមានកម្រិតរបស់រាជរដ្ឋាភិបាល នូវសុវត្ថិភាពសង្គមជូនដល់កម្មករ-កម្មការិនីដែលបាត់បង់ការងារ បានក្លាយជាអាទិភាពដ៏ចម្បងមួយទៀតរបស់យើង ក្នុងពេលនេះ ។ ក្នុងស្មារតីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំពុងធ្វើការពិភាក្សាជាបន្ទាន់ជាមួយនឹងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិនិត្យផ្តល់កញ្ចប់ថវិកាបន្ថែម ក្នុងទំហំមួយសមស្របតាមលទ្ធភាពរបស់ថវិកាជាតិ ក្នុងទិសដៅរៀបចំមូលនិធិអាហារូបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈពិសេសមួយ សម្រាប់ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី ដល់យុវជននិងកម្មករដែលបាត់បង់ការងារ ។ គោលដៅចម្បងនៃកម្មវិធីអាហារូបករណ៍នេះ គឺម្យ៉ាងជាការធានាផ្តល់នូវសុវត្ថិភាពសង្គមក្នុងកំរិតអប្បបរមាមួយ ក្នុងរយៈពេលខ្លីជូនដល់យុវជន និង កម្មករដែល បាត់បង់ការងារផង និងម្យ៉ាងទៀតជាការប្រើប្រាស់កាលានុវត្តភាពនេះ ដើម្បីជួយបង្កើនផលិតភាពការងារ ឬជួយ បណ្តុះបណ្តាល ប្តូរជំនាញរបស់ក្មួយៗយុវជន និង កម្មករ សម្រាប់ត្រៀមបំពេញការងារ ឬបង្កើតការងារដោយខ្លួនឯង នៅតាមវិស័យផ្សេងៗ ទាំងនៅទីក្រុងនិងទីជនបទ រួមទាំងលទ្ធភាពទៅបំពេញការងារនៅក្រៅប្រទេសផងដែរ នាពេលអនាគតខាងមុខ ។ប្រការដែលចាំបាច់មួយទៀតនៅក្នុងនេះ គឺការផ្សាភ្ជាប់កម្មវិធីនេះទៅនឹងប្រព័ន្ធទិន្នន័យការងារ និង មជ្ឈមណ្ឌលជួយរកការងាររបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។ ដោយសមត្ថភាពថវិការបស់រាជរដ្ឋាភិបាលមានកម្រិត រាជរដ្ឋាភិបាលបានសុំអោយដៃគូអភិវឌ្ឍន៍ទាំងឡាយ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមផ្តល់ការឧត្ថម្ភគាំទ្រចំពោះគំនិតផ្តួចផ្តើមនេះ ។

27. នៅក្នុងកាលៈទេសៈលំបាកដូចបច្ចុប្បន្ន ការយោគយល់គ្នារវាងកម្មករ និងនិយោជក ដើម្បីការពារផលប្រយោជន៍រួម ជាពិសេសការចូលរួមពីសំណាក់កម្មករខ្លួនឯងផ្ទាល់ ដើម្បីថែរក្សាការងារគឺជាប្រការដែលមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ។ ក្នុងស្មាតីនេះ រាជរដ្ឋាភិបាល បានអំពាវនាវជាថ្មីម្តងទៀត ដល់បណ្តាសហជីព និងកម្មករ-កម្មការិនីទាំងអស់ ព្រមទាំងនិយោជក ម្ចាស់រោងចក្រសហគ្រាស សូមឱ្យលើកតម្កើងស្មាតីនៃការយោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍រៀងៗខ្លួន និងដើម្បីផលប្រយោជន៍រួមរបស់ជាតិទាំងមូលផងដែរ។

28. ដោយសារវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោក វិស័យទេសចរណ៍កម្ពុជា ត្រូវទទួលរងនូវការធ្លាក់ចុះមួយចំនួននៅចុងឆ្នាំ ២០០៨ កន្លងទៅ ។ ក៏ប៉ុន្តែថ្មីៗនេះ និន្នាការងើបឡើងខ្លះនៃលំហូរទេសចរណ៍ចូលមកកម្ពុជា ពិសេសគឺចូលមកសៀមរាបអង្គរ ។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការពង្រឹងវិស័យទេសចរណ៍នេះ ទាំងនៅក្នុងរយៈពេលខ្លី មធ្យម និង វែង ខាងមុខ តាមរយៈការធានាយ៉ាង

គត់មត់នូវសន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ទេសចរណ៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែម ការកែលំអក្របខ័ណ្ឌគតិយុត្តិ និង សមត្ថភាពស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្ស និង ការធ្វើពិពិធកម្មទីផ្សារទេសចរណ៍ ។ល។

### III.4.3. ការអនុវត្តចលនាការនៃប្រព័ន្ធតួអង្គ

29. រាជរដ្ឋាភិបាល បានចាត់តាំង ក្រោមការដឹកនាំរបស់គណៈកម្មាធិការគោលនយោបាយ និង ហិរញ្ញវត្ថុ ឱ្យគ្រប់តួអង្គ ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ជួបជុំគ្នាដោះស្រាយកញ្ចប់បញ្ហាក្នុងវិស័យរៀងៗខ្លួន ។ តួអង្គសំខាន់ៗនៃប្រព័ន្ធមានបួនប្រភេទ:

- ប្រតិបត្តិករនៃវិស័យ ឬ ម្ចាស់នៃវិស័យ
- ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធ ក្នុងនោះមានទាំងធនាគារជាតិនៃកម្ពុជាផង
- ធនាគារពាណិជ្ជ ដែលធ្លាប់ ឬប្រុងហក់ចូល ដើម្បីធ្វើហិរញ្ញប្បទានដល់វិស័យ
- ដៃគូអភិវឌ្ឍន៍

30. កិច្ចដំណើរការសំរាប់វិស័យកាត់ដេរ ប្រព្រឹត្តទៅនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៩ ។ ឯកិច្ចដំណើការសំរាប់វិស័យទេសចរណ៍ ប្រព្រឹត្តទៅនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។ ជាគោលការណ៍តួអង្គ ពាក់ព័ន្ធទាំងអស់លេងល្បែងនេះ ហើយភាគីនីមួយៗសុទ្ធតែអ្នកឈ្នះ ។ រាជរដ្ឋាភិបាល មានជំនឿថាចំណាត់ការ តាមរយៈចលនាការនៃប្រព័ន្ធតួអង្គនេះ នឹងសំរាលបានមួយកំរិតទៀតនូវផលវិបាកអាក្រក់ដែលជះមកលើវិស័យ ទាំងពីរនេះ ។

### III.4.4 ការបន្តកំណែទំរង់រចនាសម្ព័ន្ធ

31. រាជរដ្ឋាភិបាល ប្តេជ្ញាបន្តគ្រប់ការដ្ឋានកំណែទំរង់ និងការដ្ឋានអភិវឌ្ឍន៍ទាំងអស់ ដោយឥតទម្លាក់ក្នុងក្របខ័ណ្ឌ «យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី២» របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ យ៉ាងណាមិញ គណៈកម្មាធិការសម្របសម្រួល រាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ (GDCC ) នឹងប្រជុំពិនិត្យការដ្ឋានទាំង១៩ នាថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ នេះ ។ មួយវិញទៀតក្រុមការងារចំរុះរាជរដ្ឋាភិបាល-ផ្នែកឯកជនទាំង៨ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន បន្តការងារខ្លួនជាប្រចាំដើម្បីដោះស្រាយរាល់បញ្ហាទាក់ទិននៅនឹងការអភិវឌ្ឍន៍ផ្នែកឯកជន ពិសេសវិនិយោគធុរកិច្ច សម្រួលពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម និងការចូលរួមនៃផ្នែកឯកជនក្នុងការសាងសង់រចនាសម្ព័ន្ធ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសម្បទាន ។

អាស្រ័យហេតុនេះសូមសម្តេចប្រធានរដ្ឋសភា មេត្តាជ្រាប និងអនុញ្ញាតតាមសំណើខាងលើ ហើយសូមផ្តល់អត្ថបទនេះ ចំពោះឯកឧត្តមតំណាងរាស្រ្ត សុន ឆ័យ ដោយអនុគ្រោះ ។

សូមសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពស់ខ្ពស់ បំផុតរបស់ខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន:</u>

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- លោកជំទាវឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ
- លោកជំទាវរដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី